# លិខិតអញ្ជើញ

ការព្យាបាលតាមបែប សក្ខីកម្ម



# ការព្យាបាលតាមបែបសក្ខីកម្មជាមួយចាម

*ជាដើមបណ្តឹងករណី ០០២ នៃ*

*អង្គជំនុំជំរះវិសាមញ្ញនៃតុលាការកម្ពុជា(អ.វ.ត.ក)*

| | |
|---|---|
| កាលបរិច្ឆេទ៖ | ថ្ងៃ សុក្រ ទី ២០ ខែ ឧសភា ឆ្នាំ ២០១៦ |
| ម៉ោង៖ | ៨៖០០ ព្រឹក |
| ទីកន្លែង៖ | វិហារឥស្លាមភូមិប្រាំ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ |
| របៀបវារៈ៖ | ៨៖០០ ព្រឹក កិច្ចស្វាគមន៍ និង សេចក្តីណែនាំ |
| | ៩៖៣០ ព្រឹក ការប្រគល់សក្ខីកម្ម |
| | ១០៖០០ ព្រឹក ពិធីព្យាបាលតាមបែបសាសនា |

## សាវតា

ការព្យាបាលតាមបែបសក្ខីកម្ម គឺជាវិធីព្យាបាលការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ មួយបែប ប្រើរយៈពេលខ្លី បង្កើតឡើងសំដៅ ធ្វើឲ្យប្រសើរឡើង នូវលទ្ធភាពដោះស្រាយផ្លូវចិត្ត ក៏ដូចជាកាត់បន្ថយរោគសញ្ញានៃជំងឺបាក់ស្បាត ក្រោយពីបានទទួលរងអំពើទារុណកម្ម ឬ អំពើហិង្សានយោបាយកើតឡើងក្នុងទំរង់ផ្សេងៗ។ ការព្យាបាលតាមបែបសក្ខីកម្មនេះ បានបង្កើត និង អធិប្បាយលើកដំបូង នៅឆ្នាំ១៩៨៣ ដោយអ្នកចិត្តវិទ្យានៃប្រទេស«ឈីលី»ក្នុងអំឡុងពេលនៃ របបជិះជាន់។ ការព្យាបាលបែបសក្ខីកម្មនេះត្រូវបានគេកែលំអ ដោយដាក់បញ្ចូលទិដ្ឋភាពវប្បធម៌ដ៏សំខាន់ៗ នៃទីកន្លែងផ្សេងៗ ជុំវិញពិភពលោក រួមមាន វប្បធម៌នៃបណ្តាប្រទេសសមាគមអាស៊ាន ដូចជា ឥណ្ឌា ស៊ីរីលង្ការ កម្ពុជា និង ហ្វីលីពីន។ អង្គការចិត្តសង្គមអន្តរវប្បធម៌នៅកម្ពុជា (ធីភីអូ កម្ពុជា) បានកែលំអការព្យាបាលបែបសក្ខីកម្មនេះ ដោយបញ្ចូលវិធីប្រតិបត្តិតាមទំនៀមទំលាប់ និង សាសនាដែលជាលទ្ធផល គឺជំរុញកម្លាំងដោះស្រាយផ្លូវចិត្តយ៉ាងធំ តាមទំនៀមទំលាប់បុរាណ រួមទាំងការជាសះផ្លូវចិត្តផ្អែកលើវប្បធម៌របស់ប្រទេសខ្លួន។

ក្នុងអំឡុងពេលព្យាបាលបែបសក្ខីកម្ម អង្គការធីភីអូ បានអញ្ជើញជនរងគ្រោះ មករំលឹកឡើងវិញ នូវបទពិសោធន៍ជីវិត រន្ធត់ៗពីអតីតកាលរបស់ខ្លួន នៅក្នុងជំនួបជាលំដាប់ប្រកបដោយភាពទុកចិត្តគ្នា ជាមួយអ្នកជំនាញប្រឹក្សាផ្លូវចិត្ត ដែលបានទទួលការបណ្តុះបណ្តាលពិសេស ។ ជំនួបទាំងឡាយនោះ ជួយជនរងគ្រោះឲ្យចងក្រងការចងចាំឡើងវិញ ហើយប្រឈមមុខតទល់នឹងអតីតកាលខ្លួន រួចប្រមូលការឈឺចាប់ទាំងឡាយ មកលាតត្រដាងជាមួយគ្នាមុនពេលដាក់ទៅក្នុងកំណត់ត្រាជាឯកសារសរសេរដែលមានឈ្មោះថា «សក្ខីកម្ម»។ បន្ទាប់មក សេចក្តីសង្ខេបនៃរឿងរ៉ាវជាបុគ្គល«សក្ខីកម្មសង្ខេប» ត្រូវគេយកទៅអានឮៗ ក្នុងពិធីសាសនាពិសេសមួយ រួចជាចុងក្រោយ ពួកគាត់ទទួលយកសក្ខីកម្មខ្លួននោះពីមនុស្សជាទីគោរពក្នុងសាសនារបស់ពួកគេមកវិញជាមួយការប្រសិទ្ធិពរជ័យជាច្រើន។ ពិធីសាសនានេះធ្វើឡើងដោយមានវត្តមាន ជនរងគ្រោះផ្សេងទៀត អ្នកស្តាប់ដែលបានអញ្ជើញ ឬ វត្តមានសាច់ញាតិ សមាជិកសហគមន៍ រដ្ឋអំណាចមូលដ្ឋាន និង យុវជនជំនាន់ក្រោយ។ តាមរយៈសកម្មភាព យ៉ាងសាមញ្ញ គឺ ចូលរួមចំណែកស្តាប់បទពិសោធន៍ជីវិតរបស់ជនរងគ្រោះ មានន័យថាអ្នកចូលរួម ជួយផ្តល់តម្លៃដល់ការឈឺចាប់ពួកគាត់ ហើយជួយសំរាលការឈឺចាប់ទាំងនោះទៀតផង។ សំរាប់ជនរងគ្រោះវិញ ពិធីបន់ស្រន់ធ្វើឲ្យព្រលឹងបុព្វការីជនរបស់ខ្លួនបានស្ងប់ ហើយក៏ជាការគោរពដល់អ្នកដែលបានស្លាប់ទៅទាំងឡាយផងដែរ។ យើងខ្ញុំមានកិត្តិយសសូមគោរពអញ្ជើញ លោក លោកស្រី អ្នកនាង កញ្ញា មកចូលរួមក្នុងពិធីព្យាបាលនេះ ដោយក្តីសោមនស្ស។

អង្គការ ធីភីអូ សហការជាមួយ អង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក. មានបំណងលើកកំពស់ ការទទួលបានសេវាសុខភាពផ្លូវចិត្តនិងសេវាផ្លូវច្បាប់ ដល់ដើមបណ្តឹងរដ្ឋប្បវេណី ក្រោមការឧបត្ថម្ភដ៏សប្បុរសពីសំណាក់ **កិច្ចសហប្រតិបត្តិការអន្តរជាតិប្រទេសអាល្លឺម៉ង់** (GIZ)។

សំរាប់ព័ត៌មានលំអិតសូមទាក់ទង កញ្ញា សុគន្ធណារ៉ា *Tel: 012 216 625* ឬ អ្នកស្រី សូលីដា *Tel: 012 306 425* ឬ

*www.tpocambodia.org* and *www.facebook.com/tpocambodia*